សេចក្តីជូនដំណឹងពីសាលា
បឋមសម្រាប់ខែកញ្ញា ឆ្នាំ២០១៨

អ៊ិនធើណេសិនណល ស្គូល អហ្វ សៀមរាប
International School of Siem Reap

Vol:3
Issue:2







# សេចក្តីជូនដំណឹងពីសាលាបឋមសម្រាប់ខែកញ្ញា ឆ្នាំ២០១៨

## អំពីការជួបជុំមាតាបិតា និងអាណាព្យាបាលសិស្ស

ការជួបជុំមាតាបិតាសិស្សប្រព្រឹត្តទៅដោយរលូន នាងខ្ញុំសូមថ្លែងអំណរគុណចំពោះការអញ្ជើញចូលរួមពីសំណាក់លោក-លោកស្រីកាលពីទី៧ ខែកញ្ញាកន្លងទៅ។ យើងខ្ញុំទាំងអស់គ្នាសប្បាយចិត្តដែលឃើញលោក-លោកស្រីមានចំណាប់អារម្មណ៍ដើរពិនិត្យថ្នាក់រៀន ហើយបានជួបជាមួយលោកគ្រូ អ្នកគ្រូក្នុងឆ្នាំសិក្សាថ្មីនេះ។ ដោយឡែកលោកគ្រូអ្នកគ្រូក៏មានភាពរីករាយក្រោយបានទទួលជួបជាមួយមាតាបិតា អាណាព្យាបាលសិស្សហើយទទួលបានគំនិតយោបល់ល្អៗសម្រាប់ធ្វើការកែលំអលើកម្មវិធីសិក្សាក្នុងពេលខាងមុខ។ ក្នុងឱកាសជួបជុំនេះសាលាក៏ទទួលបានគំនិតយោបល់ព្រមទាំងការកោតសរសើរជាច្រើនពីសំណាក់មាតាបិតាសិស្សផង។ កម្មវិធីជួបជុំមាតាបិតាគឺជាឱកាសល្អមួយដែលអាចឲ្យលោកគ្រូអ្នកគ្រូ និងអាណាព្យាបាលទាំងអស់អាចពិភាក្សាយោបល់គ្នាកំឡុងពេលញុំាអាហារ សម្រន់ដែលបង្កើតភាពស្និទស្នាលជាងនៅក្នុងថ្នាក់រៀន។ នាងខ្ញុំសង្ឃឹមថានឹងអាចជួបលោក-លោកស្រីក្នុងកម្មវិធីរបស់សាលាអន្តរជាតិ ISSR ទៀតក្នុងពេលឆាប់ៗ។

## អំពីកម្មវិធីបណ្ណាល័យសិក្សា ថ្ងៃទី០១ ដល់ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨



សាលាអន្តរជាតិISSR នឹងរៀបចំកម្មវិធីបណ្ណាល័យសិក្សាប្រចាំឆ្នាំ ដែលមានការបង្ហាញសកម្មភាពផ្សេងៗក្នុងបណ្ណាល័យ ព្រមទាំងកម្មវិធីអានសៀវភៅ។ ប្រធានបទក្នុងឆ្នាំសិក្សាថ្មីនេះគឺ "មូលហេតុដែលខ្ញុំស្រលាញ់បណ្ណាល័យក្នុងសាលា"។ សកម្មភាពសិក្សាផ្សេងៗនឹងមានការរៀបចំពីប្រភពខ្លឹមសាររបស់សៀវភៅ ហើយសាលានឹងមានការរៀបចំស្លៀកពាក់ទៅតាមតួរអង្គក្នុងសាច់រឿងសៀវភៅមួយថ្ងៃ។ ដូចនេះសិស្សអាចជ្រើសរើសតួរអង្គម្នាក់ ឬសកម្មភាពមួយពីសៀវភៅដែលពួកគេអានមកធ្វើការស្លៀកពាក់។ សកម្មភាពបន្ទាប់សិស្សនឹងធ្វើការប្រឡងអានដើម្បី រកអ្នកដែលមានសមត្ថភាពលើការអាន។ ក្នុងថ្ងៃនេះដែរ លោក-លោកស្រីអាចអញ្ជើញចូលរួមអានសៀវភៅដល់សិស្សក្នុងថ្នាក់ ហើយលោក-លោកស្រីអាចជ្រើសរើសជាភាសាអង់គ្លេស ឬជាភាសាខ្មែរក៏បាន។ សម្រាប់ព័ត៌មានលំអិតសាលានឹងចេញជាលិខិតដើម្បីផ្តល់ដំណឹងជូនលោក-លោកស្រីក្នុងពេលដ៏ខ្លីខាងមុខ។

## អំពីការចាកចេញមាតុភាពរបស់នាយកបឋមសិក្សា

ជូនចំពោះលោក-លោកស្រីជាទីគោរព ការឈប់សម្រាកមាតុភាពរបស់នាងខ្ញុំក៏បានខិតជិតមកដល់ហើយ។កូនស្រីខ្ញុំនឹងប្រសូត្រនៅចុងខែតុលា ឆ្នាំ២០១៨នេះ ដូចនេះថ្ងៃឈប់សម្រាករបស់នាងខ្ញុំគឺនៅថ្ងៃទី០៥ ខែតុលា មុនថ្ងៃបុណ្យភ្ជុំបិណ្ឌ។ កុំឡុងដែលខ្ញុំអវត្តមាន កិច្ចការជាច្រើនខ្ញុំបានប្រគល់ជូនអ្នកតំណាងដែលនាងខ្ញុំមានទំនុកចិត្តថាអាចដឹកនាំកិច្ចការបានល្អ។ អ្នកស្រី CHRIS ប្រធានក្រុមសិស្សថ្នាក់តូច លោក PHILIP ប្រធានក្រុមសិស្សថ្នាក់តូចកំរិត២ និងលោក GLEN ប្រធានក្រុមសិស្សថ្នាក់ធំ ពួកគាត់ទាំងបីនាក់គឺមានសមត្ថភាពពេញលេញក្នុងការដឹកនាំកិច្ចការជំនួសនាងខ្ញុំបណ្តោះអាសន្ន។ ពួកគាត់បានជួបជាមួយខ្ញុំនឹងពិភាក្សាអំពីកិច្ចការនានាអស់រយះពេល១ខែទៅ២ខែរួចរាល់ហើយ។ ប្រសិនបើលោក-លោកស្រីចង់ដឹងឬមានជាសំណួរផ្សេងសូមសាកសួរពួកគាត់ គ្រប់ពេលវេលា។ សំណែកខាងផ្នែករដ្ឋបាលក៏អាចផ្តល់ព័ត៌មានជូនលោក-លោកស្រីបានដូចគ្នា។ ជាចុងក្រោយ នាងខ្ញុំក៏សូមថ្លែងអំណរគុណដល់មាតាបិតា និងអាណាព្យាបាលទាំងអស់ដែលបានផ្តល់ការណែនាំល្អៗ អំពីការថែទាំសុខភាព នឹងរក្សាខ្លួនកំឡុងពេលមានផ្ទៃពោះ។ នាងខ្ញុំនិងស្វាមីពិជាអរគុណនូវបំណងល្អទាំងនេះ។ នាងខ្ញុំក៏មិនភ្លេចទេដល់នាយក នាយិកា ព្រមទាំងបុគ្គលិក ISSR ទាំងអស់ដែលបានជួយគាំទ្រក្នុងខែកន្លងទៅនេះ។ ពេលសម្រាលរួចរាល់ និងកូនមានសុខភាពល្អហើយ នាងខ្ញុំនឹងត្រឡប់មកបម្រើការជាធម្មតាវិញ។

**សាលាអន្តរជាតិ ISSR តម្រូវឲ្យសិស្សានុសិស្សទាំងអស់ញុំាអាហារសម្រន់ណាដែលមានផាសុកភាពប៉ុណ្ណោះ។ សូមលោក-លោកស្រីផ្តល់ជូនអាហារសម្រន់ណាដែលមានផាសុកភាពដល់កូនៗ ពេលមកសាលារៀន។**




*We are one,
But we are many.*

## កិច្ចការដែលសិស្សត្រូវបំពេញនៅផ្ទះ

កិច្ចការផ្ទះសិស្សត្រូវធ្វើចំនួន៣ដងក្នុងមួយសប្តាហ៍ ហើយពួកគេត្រូវបំពេញកិច្ចការទាំងនេះ។ សិស្សនឹងត្រូវចំណាយពេលជាមធ្យមគឺ៖

- ថ្នាក់ទី១ និងថ្នាក់ទី២ ចំនួន ២០នាទី ទៅ៣០នាទី
- ថ្នាក់ទី៣ និងដល់ថ្នាក់ទី៦ ចំនួន ៣០នាទី ទៅ៤០នាទី

បើតាមការស្រាវជ្រាវបានបញ្ជាក់ថាក្មេងៗដែលអាចទម្លាប់ធ្វើកិច្ចការបានទៀងទាត់ ច្បាស់លាស់ មានការកំណត់ត្រឹមត្រូវ នឹងធ្វើឲ្យពួកគេអាចរក្សាព័ត៌មានដែលបានសិក្សាពីសាលាបានល្អ។ ចំពោះកិច្ចការផ្ទះ (homework) ដែលពួកគាត់ព្យាយាមធ្វើនៅពេលយប់គឺ មិនមានផលប៉ះពាល់ទេ ពិសេសសិស្សដែលមានវ័យត្រឹមកំរិតបឋមសិក្សាបែបនេះ។ ប្រសិនបើលោក-លោកស្រីឃើញថាកូនៗធ្វើកិច្ចការផ្ទះចំណាយពេលវេលាយូរពេក ឬមានផលវិបាកក្នុងការផ្ចង់អារម្មណ៍ សូមធ្វើការទំនាក់ទំនង ឬផ្តល់ព័ត៌មានជូនគ្រូបន្ទុកថ្នាក់ដើម្បីឲ្យពួកគាត់ជួយសម្រួលស្ថានភាពតានតឹងទាំងនេះ។

ខាងក្រោមនេះគឺជា គេហទំព័រឯកសារ និយាយអំពីការជួយកូនៗក្នុងការបំពេញកិច្ចការផ្ទះបានល្អ៖

https://www.theschoolrun.com/10-top-tips-helping-your-child-homework

## អំពីក្រុមប្រឹក្សាតំណាងសិស្ស និងក្រុមបរិស្ថានស្អាត (Green Team) ក្នុងសាលា

សាលាអន្តរជាតិ ISSR នឹងបង្កើតក្រុមប្រឹក្សាតំណាងសិស្ស និងក្រុមបរិស្ថានស្អាត ដែលជ្រើសយកពីថ្នាក់ទី៣ ដល់សិស្សថ្នាក់ទី៦។ សិស្សនឹងត្រូវបានជ្រើសរើសពីការបោះឆ្នោតដើម្បីបានអ្នកតំណាងក្នុងក្រុមនីមួយៗក្នុងសប្តាហ៍នេះ រួចនឹងធ្វើការប្រកាសក្នុងកិច្ចប្រជុំប្រចាំសប្តាហ៍ដើម្បីសម្រេចអ្នកដែលត្រូវជាប់ជាក្រុមតំណាងទាំងនោះនៅក្នុងសាលា។

## ដំណឹងដ៏ក្រៀមក្រំរបស់មន្ទីរពេទ្យគន្ធបុប្ផា

សាលាអន្តរជាតិសៀមរាប ISSR មានក្តីរន្ធត់ក្នុងចិត្តយ៉ាងក្រៃលែងនិងមានការសោកស្តាយជាទីបំផុតដែលបានទទួលដំណឹងអំពីមរណភាពរបស់ Dr. MED. BEAT RICHNER នៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៨ ជាបិតាស្ថានិកនៃមន្ទីរពេទ្យគន្ធបុប្ផា ក្នុងជន្មាយុ ៧១ ឆ្នាំ ដោយរោគាពាធ។ សាលាអន្តរជាតិISSR តែងមានទំនាក់ទំនងល្អ ព្រមទាំងកោតសរសើរនូវសកម្មភាពសប្បុរសធម៌របស់លោក ។ សាលាតែងរៀបចំកម្មវិធីសប្បុរសធម៌ផ្សេងៗក្នុងការចូលរួមផ្តល់មូលនិធិដល់មន្ទីររបស់លោកផងដែរ។ សាលាបានចូលរួមសម្តែងនូវសមានទុក្ខដ៏សែនក្រៀមក្រំនៅឯមន្ទីរពេទ្យកាលពីថ្ងៃពុធកន្លងទៅនេះ។ កុមារទាំងអស់ព្រមទាំងមាតាក្នុងប្រទេសកម្ពុជានឹងនៅតែចងចាំគុណស្រ័យជាច្រើនដែលលោកបានជួយ ហើយលោកគឺជាវិរៈបុរសក្នុងបេះដូងរបស់ប្រជាពលខ្មែរជារៀងរហូត។

**តើលោក-លោកស្រីចង់ជួយកូនៗអាននៅផ្ទះប្រកបដោយភាពរលូនដែរឬទេ?**

**ជួបជាមួយអ្នកគ្រូ Chris ដែលនឹងធ្វើបទបង្ហាញជូនក្រោមប្រធានបទ “ អានផ្ទាល់ ជាមួយកូនៗ”**

កាលបរិច្ឆេទ៖ ថ្ងៃពុធ ទី០៣ ខែតុលា ឆ្នាំ២០១៨, បន្ទាប់ពីកម្មវិធី Star of The Month រួចរាល់ (វេលាម៉ោង៨:៣០នាទីព្រឹក)។

ទីតាំង៖ នៅបន្ទប់កុំព្យូទ័រអាគារ A ជាន់ទី២ ជាប់នឹងបណ្ណាល័យ

## អំពីកីឡាហែលទឹក

អាងហែលទឹកដ៏ធំរបស់សាលានឹងរួចរាល់ទាន់ពេលវេលាសម្រាប់កីឡាហែលទឹក។ គ្រូបង្វឹក លោក Didy បានត្រៀមរួចរាល់ជាស្រេចដើម្បីបង្រៀនសិស្ស ហើយកីឡានេះនឹងចាប់ផ្តើមនៅថ្ងៃចន្ទ ទី១៥ ខែតុលា ឆ្នាំ២០១៨។ លោកគ្រូអ្នកគ្រូបន្ទុកថ្នាក់នឹងផ្ញើរលិខិតព័ត៌លំអិត មកកាន់លោក-លោកស្រីនៅកម្មវិធីហែលទឹកមុនថ្ងៃបុណ្យភ្ជុំបិណ្ឌ។







ថ្នាក់ R2A កំពុងតែសិក្សាលេខពីលេខ០ ដល់លេខ២០! សូមសរសើរដែលពួកគេអាចធ្វើបាន!



សិស្សថ្នាក់ទី៤A កំពុងសិក្សាអំពីទម្រង់ខ្លាតរបស់ 3D កាលពីសប្តាហ៍មុន។

### Star of the Month

ការរៀបចំ Star of the Month ខែក្រោយគឺចាប់ផ្តើមពីម៉ោង ៨:០០ព្រឹក

- ថ្ងៃអង្គារ៍ទី**០២** ខែ **តុលា** ឆ្នាំ២០១៨៖ ថ្នាក់ Nursery និងថ្នាក់ទី១ (ថ្នាក់ R1A សម្តែង)
- ថ្ងៃពុធ ទី**០៣** ខែ**តុលា** ឆ្នាំ២០១៨៖ ថ្នាក់ទី២ ដល់ថ្នាក់ទី៦ (ថ្នាក់២B សម្តែង)

**ដំណឹងល្អ!**

ថ្នាក់បន្ថែមម៉ោង ឬកម្មវិធីបន្ថែមម៉ោង (After School Clubs) នឹងបង្កើតឡើងវិញនៅក្នុងខែមករា ឆ្នាំ២០១៩។ នាងខ្ញុំនឹងផ្តល់ព័ត៌មានបន្ថែមអំពីកម្មវិធីនេះ